ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៦៨
ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៩
សាលដីកា
លេខៈ ០៥ "I"
ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធានអង្គជំនុំជម្រះ
២.លោក [redacted] ចៅក្រម
៣.លោក [redacted] ចៅក្រម
៤.លោក [redacted] ចៅក្រមរបាយការណ៍
៥.លោកស្រី ខៀវ សុខា ចៅក្រម

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើពាក្យបណ្តឹងសាទុក្ខលេខ ៣៤០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ របស់ជនត្រូវចោទឈ្មោះ [redacted] ចរិយា ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៧៣ "ក្រ.III.ស.អ" ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដែលមាន ៖

**ជនត្រូវចោទ ៖**

១.ឈ្មោះ [redacted] ចរិយា ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ មន្ត្រីសុរិយោដី ទីកន្លែងកំណើត ភូមិទួលតាឯក ឃុំទួលតាឯក ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ទីលំនៅមុនពេលឃុំខ្លួន [redacted]



Scanned with CamScanner

[redacted] ខេត្តប៉ៃលិន ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" មានកូន ០៣នាក់ ទោសពីមុនគ្មាន (ក្នុងឃុំ) ។ (អ្នកប្តឹងសាទុក្ខ)

មេធាវីការពារសិទ្ធិ លោក [redacted] ផល្លា ។

២.ឈ្មោះ [redacted] ខាន់ ភេទប្រុស កើតថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៥៦ ជនជាតិខ្មែរ មុខរបរ មន្ត្រីចូលនិវត្តន៍ ទីកន្លែងកំណើត ភូមិលាក់ជា ឃុំព្រែកក្រឹល ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តប៉ៃលិន ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] ។

៣.ឈ្មោះ ស្រេង ហៅ ស្រី ភេទស្រី អាយុ៤០ឆ្នាំ ជនជាតិខ្មែរ ។

**ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ៖** រំលោភលើទំនុកចិត្ត និងក្លែងបន្លំ ប្រព្រឹត្តនៅភូមិគ្រង់ ភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន កាលពីអំឡុងខែមីនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ មាត្រា ៣៩២ មាត្រា ៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ ។

**ដើមបណ្តឹងរដ្ឋប្បវេណី ៖**

១.ឈ្មោះ [redacted] ពិសី ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ ទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ។

២.ឈ្មោះ [redacted] សុខុម ភេទស្រី អាយុ៥៤ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តប៉ៃលិន ។

**អំពីអង្គហេតុ ៖**

កាលពីអំឡុងខែមីនា ឆ្នាំ២០១៩ ឈ្មោះ [redacted] ពិសី ឈ្មោះ [redacted] ចរិយា ឈ្មោះ [redacted] ខេមរា ឈ្មោះ [redacted] គាឡេង និងឈ្មោះ [redacted] ធារី បានព្រមព្រៀងគ្នាចូលហ៊ុនទិញដីមួយកន្លែងមានទំហំ ២០.៤៣៩(ពីរម៉ឺនបួនរយសាមសិបប្រាំបួន)ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ពីឈ្មោះ [redacted] ទីម និងប្រពន្ធឈ្មោះ [redacted] សម្រាប់វិនិយោគ ។ ក្នុងការទិញដីនោះ គឺឈ្មោះ [redacted] ចរិយា ជាអ្នកចេញមុខចរចារជាមួយម្ចាស់ដើម ដោយប្រាប់ថាម្ចាស់គេលក់ក្នុងតម្លៃ ៣០០.០០០(សាមសិបម៉ឺន)ដុល្លារអាមេរិក ។ ពេលនោះ ឈ្មោះ [redacted] ពិសី និងម្ចាស់ភាគហ៊ុនទាំងអស់ក៏បានសម្រេចចិត្តទិញដោយឈ្មោះ [redacted] ពិសី បានធ្វើការប្រគល់ប្រាក់ឱ្យឈ្មោះ [redacted] ចរិយា ជាអ្នកចេញមុខទិញតាមដំណាក់កាល ។ ដោយលើកទី១ ប្រគល់ប្រាក់នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ចំនួន ៤៥.០០០(បួនម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ពីឈ្មោះ [redacted] ខេមរា ត្រូវជាបងស្រីរបស់ឈ្មោះ [redacted] ពិសី ហើយលើកទី២ ប្រគល់ប្រាក់នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩ ចំនួន ២៥.២០០(ពីរម៉ឺនប្រាំពាន់ពីររយ)ដុល្លារអាមេរិក ឱ្យទៅឈ្មោះ [redacted] ចរិយា ដើម្បីយកទៅប្រគល់ឱ្យម្ចាស់ដី ។ លុះដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ ឈ្មោះ [redacted] ចរិយា បានប្រាប់ឈ្មោះ [redacted] ពិសី



Scanned with CamScanner

ថាម្ចាស់ភាគហ៊ុនឈ្មោះ [redacted] គាឡេខ មានបំណងចង់លក់ភាគហ៊ុនរបស់ខ្លួនក្នុងតម្លៃ ៤០.០០០(បួនម៉ឺន) ដុល្លារអាមេរិក ហើយឈ្មោះ [redacted] ពិសី ក៏យល់ព្រមក្នុងការទិញ និងប្រគល់ប្រាក់ចំនួន ៣០.០០០(បីម៉ឺន) ដុល្លារអាមេរិក ឱ្យឈ្មោះ [redacted] ចរិយា ដើម្បីយកទៅឱ្យម្ចាស់ភាគហ៊ុនឈ្មោះ [redacted] គាឡេខ ។ ក្រោយមកនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ឈ្មោះ [redacted] ចរិយា បានទាមទារប្រាក់ចំនួន ៤៦.៥០០(បួនម៉ឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក បន្ថែមទៀត ដោយប្រាប់ថាយកទៅឱ្យម្ចាស់ដី ។ ចំពោះការទិញលក់នោះ ឈ្មោះ [redacted] ពិសី បានសុំជួបជាមួយម្ចាស់ដីផ្ទាល់ដើម្បីធ្វើលិខិតផ្ទេរសិទ្ធិតែឈ្មោះ [redacted] ចរិយា មិនព្រមឱ្យជួបទេ ។ ក្រោយមកទើបឈ្មោះ [redacted] ចរិយា បានយកមនុស្សម្នាក់ឈ្មោះ ស្រេខ ហៅ ស្រី មកក្លែងបន្លំធ្វើជាម្ចាស់ដីដើម្បីឱ្យមកទទួលប្រាក់ពីឈ្មោះ [redacted] ពិសី ដោយរាល់ជំនួបទាំងអស់គឺឈ្មោះ [redacted] ខាន់ ភេទប្រុស ជាអ្នកជូនមក ប៉ុន្តែ ឈ្មោះ [redacted] ពិសី មិនទុកចិត្ត ក៏បានទាមទារយកលិខិតផ្ទេរសិទ្ធិច្បាប់ដើមមកមើល ប៉ុន្តែឈ្មោះ [redacted] ចរិយា បានកុហកថា រង់ចាំថ្ងៃនេះ ថ្ងៃនោះ ជាច្រើនដង ។ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ឈ្មោះ [redacted] ពិសី បានជួបជាមួយម្ចាស់ពិតប្រាកដ ទើបដឹងថា ឈ្មោះ [redacted] ចរិយា មិនយកប្រាក់ដែលឈ្មោះ [redacted] ពិសី ប្រគល់ឱ្យជាបន្តបន្ទាប់ចំនួន ១៩១.៧០០(ដប់ប្រាំបួនម៉ឺនមួយពាន់ប្រាំពីររយ)ដុល្លារអាមេរិកគត់ ទៅម្ចាស់ដីទេ ព្រោះម្ចាស់ដីបានអះអាងថា ទទួលប្រាក់ត្រឹមតែ ៤០.០០០(បួនម៉ឺន)ដុល្លារអាមេរិក ប៉ុណ្ណោះ ។ ចំពោះការទិញដីខាងលើនេះ គឺម្ចាស់ដីបានព្រមព្រៀងលក់ក្នុងតម្លៃ ១៨០.០០០(ដប់ប្រាំបីម៉ឺន)ដុល្លារអាមេរិក ប៉ុណ្ណោះ ប៉ុន្តែឈ្មោះ [redacted] ចរិយា បានកុហកឈ្មោះ ហាក់ ពិសី ថាដីនេះមានតម្លៃ ៣០០.០០០(សាមសិបម៉ឺន)ដុល្លារអាមេរិក ទៅវិញ ។ ក្រោយមកឈ្មោះ [redacted] ពិសី បានសុំឱ្យឈ្មោះ [redacted] ចរិយា ប្រគល់ឯកសារថ្លៃដីទិញលក់ឱ្យមកឈ្មោះ [redacted] ពិសី តែឈ្មោះ [redacted] ចរិយា បានប្រគល់ឯកសារកិច្ចសន្យាកក់ប្រាក់ថ្លៃទិញដីក្លែងស្នាមមេដៃអ្នកលក់ ពីព្រោះម្ចាស់ដីពិតប្រាកដបានអះអាងថា មិនមែនជាស្នាមមេដៃរបស់ពួកគាត់ឡើយ ។

-បានឃើញ ដីកាសម្រេចមិនព្រមដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំលេខ ៩១៨ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តប៉ៃលិន ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.មិនព្រមដោះលែងឱ្យនៅក្រៅឃុំចំពោះជនត្រូវចោទឈ្មោះ [redacted] ចរិយា ភេទស្រី អាយុ៣៧ឆ្នាំ ជាតិខ្មែរ ។

២.ត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ និងឃុំខ្លួនពីបទ រំលោភលើទំនុកចិត្ត និងការក្លែងបន្លំ ប្រព្រឹត្តនៅចំណុចភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន កាលពីអំឡុងខែមីនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ មាត្រា ៣៩២ មាត្រា ២៦២ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។



Scanned with CamScanner

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១១ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ របស់លោក [redacted] មន្ត្រីមេធាវី ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ចរិយា ដែលប្តឹងមិនសុខចិត្តនឹងដីកាសម្រេចមិនព្រមដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំលេខ ៤១៨ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តប៉ៃលិន ត្រង់ចំណុច នៃដីកាសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៧៣ "ក្រ.III.ស.អ" ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរ នៃសាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ១១ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ របស់មេធាវី [redacted] មន្ត្រីមេធាវី មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ចរិយា គឺត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះមូលដ្ឋានគតិច្បាប់ ។

២.តម្កល់ដីកាសម្រេចមិនព្រមដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំលេខ ៤១៨ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តប៉ៃលិន ទុកជាបានការដដែល ។

សាលដីកានេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ ។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៣៤០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ របស់ជនត្រូវចោទឈ្មោះ [redacted] ចរិយា ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៧៣ "ក្រ.III.ស.អ" ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា ៖

-ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ ដែលតម្កល់ដីកាសម្រេចមិនព្រមដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ទុកជាបានការដដែលនោះ គឺមានសំអាងហេតុត្រឹមត្រូវតាមច្បាប់ ព្រោះថា ៖

-ការឃុំខ្លួន គឺជាការចាំបាច់ ដូចមានក្នុងសំអាងហេតុចំណុចទី៣ និងទី៥ នៃសាលដីកាសាលាឧទ្ធរណ៍ស្រាប់ ។

ហេតុដូច្នេះ

តំណាងមហាអយ្យការ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច

សុំតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៧៣ "ក្រ.III.ស.អ" ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។



Scanned with CamScanner

ជនជាប់ចោទឈ្មោះ [redacted] ចរិយា បានឆ្លើយថា ៖ នាងខ្ញុំកើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨២ មុខរបរមន្ត្រីសុរិយោដីខេត្តប៉ៃលិន ។ សព្វថ្ងៃឃុំខ្លួននៅពន្ធនាគារខេត្តបាត់ដំបង ក្នុងរឿងនេះ នាងខ្ញុំទុកសិទ្ធិឱ្យលោកមេធាវីធ្វើសេចក្តីសន្និដ្ឋាន ។

លោក [redacted] ផល្លា មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ចរិយា បានធ្វើសេចក្តីសន្និដ្ឋានថា ៖ ចំពោះការប្តឹងសាទុក្ខមកនេះ កូនក្តីខ្ញុំមានមូលហេតុដូចជា ៖

ទី១ សាលាឧទ្ធរណ៍ មិនបានពិចារណាឱ្យបានត្រឹមត្រូវ ។

ទី២ ពាក់ព័ន្ធបទល្មើសតាមដីកាបញ្ជូនជារឿងបទល្មើសមជ្ឈិម មិនមែនបទឧក្រិដ្ឋទេ ។

ទី៣ សព្វថ្ងៃគាត់មានកូនពាក់ បច្ចុប្បន្នជួបជីវភាពលំបាក ។

ទី៤ ការប្តឹងរឿងរដ្ឋប្បវេណី ភាគីម្ខាងប្តឹងទាមទារប្រាក់ គឺកូនក្តីខ្ញុំគាត់បានទទួលស្គាល់អស់ហើយ ។

ទី៥ កូនក្តីខ្ញុំបាទបំពេញកាតព្វកិច្ចអស់ហើយកូនក្តីខ្ញុំឃុំខ្លួនលើស៤ខែ ។

សំណូមពរ ៖ សុំឱ្យកូនក្តីខ្ញុំនៅក្រៅឃុំ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនត្រូវចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនត្រូវចោទ
- ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៤០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ របស់ជនត្រូវចោទឈ្មោះ [redacted] ចរិយា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧ មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលសភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចតម្កល់ដីកាសម្រេចមិនព្រមដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំលេខ ៤១៨ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តប៉ៃលិន ដោយលើកសំអាងហេតុថា "បទចោទប្រកាន់ចំពោះជនត្រូវចោទជាបទមជ្ឈិមជាច្រើនបទល្មើស ការស៊ើបសួរមិនទាន់បញ្ចប់ ជនត្រូវចោទបានប្រព្រឹត្តបទល្មើសច្រើន បានរត់គេចខ្លួន អំពើរបស់ជនត្រូវចោទអាចធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ចូលក្នុងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ដើម្បីបញ្ចប់ ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី និងរារាំងកុំឱ្យមានការ



Scanned with CamScanner

គាបសង្កត់លើសាក្សី ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដោយសារបទល្មើស និងដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី គប្បីក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ និងសម្រេចបដិសេធចោលពាក្យបណ្តឹងឧទ្ធរណ៍ដូចខាងលើ" ។ ការសំអាងហេតុដូចនេះជាការពុំត្រឹមត្រូវទេ ពីព្រោះពុំមានភស្តុតាងបញ្ជាក់អំពីហេតុដែលអាចនាំឱ្យជនត្រូវចោទធ្វើការគាបសង្កត់លើសាក្សី ឬមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទជាមួយនឹងអ្នកសមគំនិត មានការច្របូកច្របល់ដោយសារបទល្មើសនេះនោះទេ។ ផ្ទុយទៅវិញជនត្រូវចោទ បានសារភាព ទទួលស្គាល់នូវកំហុស ទទួលស្គាល់ពីចំនួនប្រាក់ដែលខ្លួនគាត់ទទួលពីដើមបណ្តឹងរដ្ឋប្បវេណី និងបានសន្យាសងគ្រប់ចំនួនវិញទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីទៀតផង ។ ម្យ៉ាងទៀត សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ មិនបានពិចារណាអំពីស្ថានភាពជាក់ស្តែងរបស់ជនត្រូវចោទ ដែលបានលើកឡើងដោយមេធាវីការពារក្តីរបស់ជនត្រូវចោទ ដែលភ្ជាប់ជាមួយនូវភស្តុតាងបញ្ជាក់នៅចំពោះមុខសភាស៊ើបសួរសាលាឧទ្ធរណ៍ ក៏ដូចជានៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនេះថា ជនត្រូវចោទមានមុខរបរច្បាស់លាស់ គាត់ជាមន្ត្រីនៃមន្ទីរសុរិយោដីខេត្តប៉ៃលិន គាត់មានកូនតូចៗចំនួន ០៣នាក់ ក្នុងបន្ទុក ហើយក្នុងរឿងផ្នែកសំណងរដ្ឋប្បវេណីវិញ សាលាដំបូងខេត្តប៉ៃលិនបានចេញ ដីកាសម្រេចរក្សាការពារ ហាមឃាត់ទ្រព្យសម្បត្តិជាអចលទ្រព្យរបស់ជនត្រូវចោទចំនួន ០៣កន្លែង ដែលមានតម្លៃលើសពីចំនួនទឹកប្រាក់នៃការខូចខាតដែលកើតចេញពីការប្រព្រឹត្តរបស់ជនត្រូវចោទ ក្នុងករណីតុលាការអង្គសេចក្តី រកឃើញថាមានកំហុស ។

មិនតែប៉ុណ្ណោះ តាមឯកសារភស្តុតាងបង្ហាញឱ្យឃើញថា ក្នុងរឿងក្តីព្រហ្មទណ្ឌនេះ ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការប្តឹងទាមទារសំណងរដ្ឋប្បវេណីទៅតុលាការរដ្ឋប្បវេណីខេត្តប៉ៃលិន ហើយកំពុងតែស្ថិតនៅក្នុងដំណាក់កាលនីតិវិធីនៃការអនុវត្តដោយបង្ខំទៅលើទ្រព្យរបស់ជនត្រូវចោទ ដើម្បីទូរទាត់សំណងទៀតផង ។

៣-យល់ឃើញថា ផ្អែកតាមសំអាងហេតុដូចដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទពុំមានភាពចាំបាច់ស្របតាមបទប្បញ្ញត្តិមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះតទៅទៀតហើយ ពីព្រោះតាមបទប្បញ្ញត្តិមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងតែក្នុងករណីពិសេសដែលមានមូលហេតុស្របតាមបទប្បញ្ញត្តិមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌតែប៉ុណ្ណោះ ។

៤-យល់ឃើញថា ជនត្រូវចោទឈ្មោះ [redacted] ចរិយា ត្រូវបានជាប់ក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន តាមអំណាចដីកាបង្គាប់ឱ្យឃុំខ្លួនរបស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តប៉ៃលិន ចាប់តាំងពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០១៩ រហូតមកដល់ពេលនេះ ជនត្រូវចោទបានជាប់ឃុំខ្លួនអស់រយៈពេល ៥ ខែ និង ២៤ ថ្ងៃ ហើយ យោងតាមបទប្បញ្ញត្តិមាត្រា ២០៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបញ្ញត្តិអំពីថិរវេលានៃការឃុំខ្លួនជាបណ្តោះ

Scanned with CamScanner

វាសន្នក្នុងបទមជ្ឈិមថា "ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទមជ្ឈិម ការឃុំខ្លួនជាបណ្ដោះអាសន្នមិនអាចលើសពី៤(បួន)ខែ បានទេ" ។ ដូច្នេះឃើញថា ជនត្រូវចោទរូបនេះត្រូវបានឃុំខ្លួនលើសកំណត់ច្បាប់រហូតដល់រយៈពេល ១ ខែ និង ២៤ ថ្ងៃ ហើយ ដែលជាមូលហេតុចាំបាច់ត្រូវតែសម្រេចដោះលែងឱ្យមានសេរីភាព ។

៥-យល់ឃើញថា សាលដីកាសភាស៊ើបសួររបស់សាលាឧទ្ធរណ៍ភ្នំពេញលេខ ៧៣ "ក្រ.III.ស.អ" ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ ដែលបានសម្រេចសេចក្ដីមកនេះ ខុសនឹងគតិច្បាប់ ។

**កត់សម្គាល់ថា តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] ចរិយា ថា បច្ចុប្បន្នខ្លួនកំពុងតែជាប់ក្នុងឃុំជាបណ្ដោះអាសន្ននៅពន្ធនាគារខេត្តបាត់ដំបង តាមអំណាចដីកាបង្គាប់ឱ្យឃុំខ្លួនរបស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តប៉ៃលិនលេខ ៣១៥ ត.ព្រ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ តាមការចាត់ចែង សម្របសម្រួលរបស់អគ្គនាយកដ្ឋានពន្ធនាគារ ។

## ហេតុដូច្នេះ

## សម្រេច

១-ទទួល បណ្ដឹងសាទុក្ខលេខ ៣៤០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ របស់ជនត្រូវចោទឈ្មោះ [redacted] ចរិយា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធ សាលដីកាព្រហ្មទណ្ឌលេខ ៧៣ "ក្រIII.ស.អ" ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ។

៣-ដោះលែង ជនត្រូវចោទឈ្មោះ [redacted] ចរិយា ឱ្យនៅក្រៅការឃុំខ្លួន ប្រសិនបើជននេះមិនត្រូវបានជាប់ឃុំខ្លួនពីបទល្មើសផ្សេងទៀតនោះទេ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រ ទី១០ ខែមករា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃសុក្រ ទី១៧ ខែមករា ឆ្នាំ២០២០ ។

Scanned with CamScanner